# آداب السفر وأحكامه

# សុជីវធម៌

# និងក្បួនច្បាប់នៃការធ្វើដំណើរ

# សុជីវធម៌ និងក្បួនច្បាប់នៃការធ្វើដំណើរ

الحمد لله رب العالمين، والصلاة والسلام على نبينا محمد، وعلى آله وصحبه أجمعين

أما بعد:

នេះគឺជាសារសង្ខេបខ្លីមួយទាក់ទងនឹងសុជីវធម៌និងក្បួនច្បាប់នៃការធ្វើដំណើរ។ នៅក្នុងសារនេះ យើងព្យាយាមពន្យល់បកស្រាយនូវអ្វីដែលអ្នកដំណើរត្រូវការដឹងជាចម្បង។

យើងសូមបួងសួងពីអល់ឡោះជាម្ចាស់សូមទ្រង់មេត្តាធ្វើឱ្យការងារនេះមានភាពបរិសុទ្ធជ្រះថ្លាសម្រាប់ទ្រង់ និងសូមឲ្យបានជាប្រយោជន៍ដល់ជនមូស្លីមទូទៅ។

គណៈកម្មាធិការនៃអង្គការបម្រើការមាតិកាអ៊ីស្លាមជាភាសានានា

## ទីមួយៈ សុជីវធម៌នៃការធ្វើដំណើរ

ចំពោះអ្នកដែលធ្វើដំណើរទៅធ្វើធម្មយាត្រាហាជ្ជី ឬក៏ការគោរពសក្ការៈ(អ៊ុំរ៉ោះ)ផ្សេងទៀតគប្បីយកចិត្តទុកដាក់លើចំណុចដូចខាងក្រោម៖

១. សុំការណែនាំពីអល់ឡោះជាម្ចាស់ទាក់ទងនឹងពេលវេលានៃការធ្វើដំណើរ មធ្យោបាយធ្វើដំណើរ អ្នករួមដំណើរជាមួយ និងផ្លូវត្រូវជ្រើសរើសសម្រាប់ការធ្វើដំណើរនោះ ប្រសិនបើផ្លូវមានច្រើន។ គួរពិគ្រោះយោបល់ជាមួយអ្នកមានបទពិសោធន៍ និងអ្នកមានកុសល។ ចំពោះការហាជ្ជីនិងអ៊ុំរ៉ោះ

វាជាការធ្វើដំណើរដែលល្អដោយគ្មានការសង្ស័យឡើយ។ រីឯការសុំការណែនាំសុំពីអល់ឡោះ(អ៊ីស្ទីខ៏រ៉ោះ)វិញ គឺគេត្រូវសឡាតពីររ៉ក្អាត់ បន្ទាប់មកធ្វើការបួងសួងពីអល់ឡោះនូវពាក្យបួងសួង(ទូអា)ដែលមានភស្តុតាងបញ្ជាក់ពីណាពី ﷺ ។

២. ចំពោះអ្នកដែលធ្វើហាជ្ជី និងអ្នកដែលធ្វើអ៊ុមរ៉ោះចាំបាច់ត្រូវឲ្យគោលបំណងនៃការធ្វើហាជ្ជី និងអ៊ុមរ៉ោះរបស់ខ្លួន គឺដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះ និងបញ្ជិតខ្លួនទៅកាន់ទ្រង់ ហើយត្រូវប្រុងប្រយ័ត្នកុំឲ្យគោលបំណងរបស់គេ គឺដើម្បីផលប្រយោជន៍លោកិយ ឬក៏ដើម្បីអួតអាង ឬដើម្បីទទួលបានងារ ឋានៈ ឬក៏ដើម្បីបង្ហាញឲ្យគេបានដឹង បានឮ ព្រោះទាំងនេះ គឺជាមូលហេតុដែលធ្វើឲ្យទង្វើរបស់គេក្លាយជាអសារបង់ និងមិនត្រូវបានគេទទួលយក។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

﴿قُلْ إِنَّمَآ أَنَا۠ بَشَرٌ مِّثْلُكُمْ يُوحَىٰٓ إِلَيَّ أَنَّمَآ إِلَٰهُكُمْ إِلَٰهٌ وَٰحِدٌ فَمَن كَانَ يَرْجُوا۟ لِقَآءَ رَبِّهِۦ فَلْيَعْمَلْ عَمَلًا صَٰلِحًا وَلَا يُشْرِكْ بِعِبَادَةِ رَبِّهِۦٓ أَحَدًۢا﴾

“ចូរអ្នក(មូហាំម៉ាត់)ពោលថា៖ តាមពិតខ្ញុំជាមនុស្សលោកដូចពួកអ្នកដែរ គ្រាន់តែគេបានផ្តល់វ៉ាហ៊ីមកកាន់ខ្ញុំថា៖ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នក គឺជាព្រះជាម្ចាស់តែមួយគត់។ ដូចនេះ ជនណាហើយដែលសង្ឃឹមថា

នឹងបានជួបព្រះជាម្ចាស់របស់ខ្លួន ចូរឱ្យគេសាងទង្វើកុសល ហើយកុំឱ្យគេយកអ្នកណាម្នាក់ធ្វើជាដៃគូក្នុងការគោរពសក្ការៈចំពោះព្រះជាម្ចាស់របស់គេឱ្យសោះ”។ [អាល់កះហ្វិ៖១១០]

ចំណែកឯនៅក្នុងហាទីស្ហគុតស៊ីយ៍វិញ៖

«أَنَا أَغْنَى الشُّرَكَاءِ عَنِ الشِّرْكِ، مَنْ عَمِلَ عَمَلًا أَشْرَكَ فِيهِ مَعِي غَيْرِي تَرَكْتُهُ وَشِرْكَهُ» [1].

“យើងមិនត្រូវការស្ហ៊ីរិក(ដៃគូ)ឡើយ។ ហេតុនេះ បុគ្គលណាធ្វើទង្វើអ្វីមួយដោយស្ហ៊ីរិកមកចំពោះយើង(ដើម្បីយើងផង និងអ្នកផ្សេងផង) យើងនឹងបោះបង់គេ និងទង្វើស្ហ៊ីរិករបស់គេចោល(យើងមិនផ្តល់ផលបុណ្យឲ្យឡើយ)”។[1]

៣. ចាំបាច់លើអ្នកធ្វើហាជ្ជី និងអ្នកធ្វើអ៊ុមរ៉ោះត្រូវស្វែងយល់ពីក្បួនច្បាប់នៃការធ្វើអ៊ុមរ៉ោះនិងការធ្វើហាជ្ជី ក៏ដូចជាក្បួនច្បាប់នៃការធ្វើដំណើរមុនពេលចេញដំណើរ ដើម្បីកុំឱ្យគេបោះបង់កាតព្វកិច្ចណាមួយ ឬធ្លាក់ខ្លួនក្នុងប្រការដែលគេហាមឃាត់ណាមួយ។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ يُرِدِ اللهُ بِهِ خَيْرًا يُفَقِّهْهُ فِي الدِّينِ» [2].

---

[1] រាយការណ៍ដោយមូស្លីមៈ២៩៨៥

“បុគ្គលណាដែលអល់ឡោះប្រាថ្នាចង់ឲ្យរូបគេបានល្អ ទ្រង់នឹងឲ្យជននោះយល់ដឹងពីសាសនា(អ៊ិស្លាម)”។[2]

៤. ចាំបាច់លើអ្នកធ្វើហាជ្ជី និងអ្នកធ្វើអ៊ុមរ៉ោះត្រូវជ្រើសយកប្រាក់ដែលបានមកដោយស្របច្បាប់(ហាឡាល់)សម្រាប់ការធ្វើហាជ្ជី និងការធ្វើអ៊ុមរ៉ោះរបស់ខ្លួន ពីព្រោះអល់ឡោះជាម្ចាស់ទ្រង់ស្អាតស្អំ។ ទ្រង់មិនទទួលយកឡើយ លើកលែងតែអ្វីដែលស្អាតស្អំ និងដោយសារតែប្រាក់ដែលបានមកដោយខុសច្បាប់ (ហារ៉ាំ) គឺជាមូលហេតុដែលធ្វើឱ្យការបួងសួងមិនត្រូវបានគេទទួលយក។

៥. ត្រូវសារភាពកំហុស(តាវហ្ពាត់)ពីរាល់បាបកម្ម និងអំពើល្មើសទាំងឡាយ។ ហើយប្រសិនបើគេបានបំពានលើសិទ្ធិអ្នកដទៃ គេត្រូវបង្វិលសិទ្ធិនោះទៅម្ចាស់ដើមវិញ និងទូទាត់គ្នាឲ្យបានដាច់ស្រេចជាមួយអ្នកទាំងនោះ មិនថាសិទ្ធិនោះទាក់ទងនឹងកិត្តិយស ទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀតនោះឡើយ។

៦. ស៊ូណិតលើអ្នកដែលធ្វើដំណើរគប្បីសរសេរពាក្យបណ្ដាំ សរសេរនូវអ្វីដែលគេជំពាក់ខ្លួន

[2] រាយការណ៍ដោយអាល់ពូខរី៖២៧៣៨, មូស្លីម៖១៦២៧

និងអ្វីដែលខ្លួនជំពាក់គេ។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«مَا حَقُّ امْرِئٍ مُسْلِمٍ لَهُ شَيْءٌ يُوصِي فِيهِ يَبِيتُ لَيْلَتَيْنِ إِلَّا وَوَصِيَّتُهُ مَكْتُوبَةٌ عِنْدَهُ» [3]

“មិនមែនជាទង្វើរបស់អ្នកមានជំនឿឡើយដែលរូបគេមានអ្វីត្រូវផ្តាំផ្ញើ ហើយគេទុកឲ្យរំលងបីយប់ដោយមិនបានសរសេរបណ្តាំនោះ”។[3] ត្រូវមានសាក្សីចំពោះពាក្យបណ្តាំនោះ ត្រូវសងនូវបំណុលដែលខ្លួនជំពាក់គេ និងប្រគល់បញ្ញើដែលគេផ្ញើនឹងខ្លួនទៅម្ចាស់បញ្ញើវិញ ឬសុំការអនុញ្ញាតពីម្ចាស់បញ្ញើក្នុងការរក្សាទុកបញ្ញើនោះ។

៧. ស៊ុណិតលើអ្នកធ្វើដំណើរគប្បីព្យាយាមជ្រើសរើសមនុស្សល្អមករួមដំណើរជាមួយ និងព្យាយាមស្វែងរកអ្នកដែលមានចំណេះដឹងខាងសាសនា ព្រោះនេះជាមូលហេតុមួយដែលធ្វើឲ្យគេទទួលបានការចង្អុលបង្ហាញ និងមិនធ្លាក់ទៅក្នុងកំហុសឆ្គងក្នុងការធ្វើដំណើរ ក៏ដូចជាក្នុងការហាជ្ជីនិងការធ្វើអ៊ុមរ៉ោះរបស់គេ

3 រាយការណ៍ដោយ អាពូហ្ទាវូទ៖៤៨៣៣

ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«الرَّجُلُ عَلَى دِينِ خَلِيلِهِ، فَلْيَنْظُرْ أَحَدُكُمْ مَنْ يُخَالِلُ» [៤]؛

“មនុស្សម្នាក់ គឺស្ថិតនៅលើសាសនាមិត្តភក្តិរបស់ខ្លួន។ ហេតុនេះ ម្នាក់ៗនៃពួកអ្នកត្រូវពិនិត្យមើលថា តើនរណាដែលខ្លួនត្រូវយកធ្វើជាមិត្តភក្តិ”។[4] និងយោងតាមប្រសាសន៍របស់ណាពី ﷺ ថា៖

«لَا تُصَاحِبْ إِلَّا مُؤْمِنًا، وَلَا يَأْكُلْ طَعَامَكَ إِلَّا تَقِيٌّ» [5].

“ចូរអ្នកកុំសេពគប់ធ្វើជាមិត្តជិតស្និទ្ធលើកលែងតែអ្នកមានជំនឿ ហើយមិនត្រូវឲ្យទទួលទានចំណីអាហាររបស់អ្នកឡើយ លើកលែងតែអ្នកដែលកោតខ្លាចអល់ឡោះ”។[5]

៨. ស៊ូណិតលើអ្នកដែលធ្វើដំណើរគប្បីលាក្រុមគ្រួសារ សាច់ញាតិ អ្នកជិតខាង និងមិត្តភក្តិរបស់ខ្លួន។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ أَرَادَ أَنْ يُسَافِرَ فَلْيَقُلْ لِمَنْ يُخَلِّفُ: أَسْتَوْدِعُكُمُ اللَّهَ الَّذِي لَا يُضِيعُ وَدَائِعَهُ» [6]،

“ជនណាដែលមានបំណងធ្វើដំណើរ ចូរឲ្យគេពោលទៅកាន់អ្នកដែលមកជូនដំណើរថា៖

---

4 រាយការណ៍ដោយ អាពូហ្ទាវូទ៖៤៨៣២, អាត់តៀរមីហ្ស៊ី៖២៣៩៥

5 រាយការណ៍ដោយ អាត់តប់រ៉នី៖៨២៣

أَسْتَوْدِعُكُمُ اللَّهَ الَّذِي لَا يُضِيعُ وَدَائِعَه
(ខ្ញុំសូមពឹអល់ឡោះឲ្យទ្រង់ថែរក្សាពួកអ្នក ព្រោះទ្រង់ជាអ្នកថែរក្សាដ៏ល្អបំផុត)។[6] ណាពី ﷺ លោកតែងលាមិត្តភក្តិរបស់លោកនៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកគេត្រៀមធ្វើដំណើរ ដោយលោកពោលថា៖

«أَسْتَوْدِعُ اللهَ دِينَكَ وَأَمَانَتَكَ وَخَوَاتِيمَ عَمَلِكَ»[7]،

أَسْتَوْدِعُ اللهَ دِينَكَ وَأَمَانَتَكَ وَخَوَاتِيمَ عَمَلِكَ
"ខ្ញុំសូមផ្ទុកផ្ដាក់នឹងអល់ឡោះចំពោះសាសនារបស់ពួកអ្នក ភាពទៀងត្រង់របស់ ពួកអ្នក និងទង្វើចុងក្រោយរបស់ពួកអ្នក"។[7] ហើយណាពី ﷺ លោកតែងពោលទៅកាន់អ្នកដែលធ្វើដំណើរទាំងឡាយដែលសុំឱ្យលោកផ្ដល់ការផ្ដែផ្ដាំដល់ខ្លួនថា៖

«زَوَّدَكَ اللَّهُ التَّقْوَى، وَغفَرَ ذَنْبَكَ، وَيَسَّرَ لَكَ الخَيْرَ حَيْثُ مَا كُنْتَ» [8]

زَوَّدَكَ اللَّهُ التَّقْوَى، وَغفَرَ ذَنْبَكَ، وَيَسَّرَ لَكَ الخَيْرَ حَيْثُ مَا كُنْتَ
(សូមអល់ឡោះបន្ថែមនូវការកោតខ្លាចដល់អ្នក អភ័យទោសចំពោះបាបកម្មរបស់អ្នក និងសម្រួលនូវប្រការល្អដល់អ្នកនៅគ្រប់ទីកន្លែង)។[8] មានបុរសម្នាក់បានមកជួបណាពី ﷺ ដោយគេមានបំណងចង់ធ្វើដំណើរ ហើយគេបាននិយាយថា៖ ឱរ៉សូលុលឡោះ!

[6] រាយការណ៍ដោយអះម៉ាត់នៅក្នុងសៀវភៅមុសណាត់របស់គាត់៖៤៥២៤
[7] រាយការណ៍ដោយ អាត់តៀរមីហ្សី៖៣៤៤៤
[8] រាយការណ៍ដោយអះម៉ាត់នៅក្នុងសៀវភៅមុសណាត់របស់គាត់៖៩៧២៤

សូមផ្ដល់ការផ្ដាំផ្ញើដល់ខ្ញុំផង។ ពេលនោះ លោកបានមានប្រសាសន៍ថា៖

**«أُوصِيكَ بِتَقْوَى اللهِ، وَالتَّكْبِيرِ عَلَى كُلِّ شَرَفٍ» فَلَمَّا مضَى قَالَ: « اللَّهُمَّ ازْوِ لَهُ الْأَرْضَ، وَهَوِّنْ عَلَيْهِ السَّفَرَ» [9].**

“ខ្ញុំសូមផ្ដាំផ្ញើអ្នកឲ្យកោតខ្លាចអល់ឡោះ និងតឹកពៀរ(សូត្រថា៖ الله أكبر)នៅរាល់ពេលឡើងទីខ្ពស់”។ នៅពេលបុរសនោះចេញទៅ លោកបានបួងសួងថា៖ “ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាបង្រួញផែនដីសម្រាប់គាត់ និងឱ្យការធ្វើដំណើររបស់គាត់មានភាពងាយស្រួលផង”។[9]

៩. មិនត្រូវយកកណ្ដឹង ឧបករណ៍ភ្លេង និងឆ្កែរួមដំណើរទៅជាមួយឡើយ ដោយយោងតាមហាទីស្អាពូហ៊ូរ៉យរ៉ោះ رضي الله عنه ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

**«لَا تَصْحَبُ الْمَلَائِكَةُ رُفْقَةً فِيهَا كَلْبٌ وَلَا جَرَسٌ» [10].**

“ម៉ាឡាអ៊ីកាត់មិនរួមដំណើរជាមួយក្រុមណាដែលមានឆ្កែ ឬកណ្ដឹងឡើយ”។[10]

---

9 រាយការណ៍ដោយ មូស្លីម៖២០១៣

10 រាយការណ៍ដោយ អាល់ពូខរី៖២៩៩៣, មូស្លីម៖២១១០

១០. ប្រសិនបើគេចង់ធ្វើដំណើរជាមួយភរិយាណាម្នាក់ ខណ:ដែលគេមានភរិយាច្រើនជាងម្នាក់ គឺគេត្រូវធ្វើចាប់ឆ្នោតរវាងពួកនាង។ ប្រសិនបើចាប់ឆ្នោតត្រូវភរិយាម្នាក់ណា ភរិយានោះត្រូវបានទៅជាមួយគេ ដោយយោងតាមហាទីស្អអាអ៊ីស្ហះ رضي الله عنها គាត់បាននិយាយថា៖

**«كَانَ رَسُولُ اللهِ صلى الله عليه وسلم: إِذَا أَرَادَ سَفَرًا أَقْرَعَ بَيْنَ نِسَائِهِ، فَأَيَّتُهُنَّ خَرَجَ سَهْمُهَا خَرَجَ بِهَا مَعَهُ» [11].**

“កាលណារ៉សូ៊លុលឡោះ ﷺ លោកចង់ធ្វើដំណើរ លោកតែងធ្វើការចាប់ឆ្នោតរវាងភរិយាទាំងឡាយរបស់លោក។ ប្រសិនបើចាប់ឆ្នោតត្រូវអ្នកណា លោកនឹងយកអ្នកនោះទៅជាមួយ”។[11]

១១. ស៊ុណិតចេញដំណើរនៅព្រឹកថ្ងៃព្រហស្បតិ៍ ប្រសិនបើអាច ដោយយោងតាមទង្វើណាពី ﷺ ។ កាអាប់ ពិន ម៉ាលិក رضي الله عنه បាននិយាយថា៖

**«لَقَلَّمَا كَانَ رَسُولُ اللهِ صلى الله عليه وسلم يَخْرُجُ إِذَا خَرَجَ فِي سَفَرٍ إِلَّا يَوْمَ الْخَمِيسِ» [12].**

រ៉សូ៊លុលឡោះ ﷺ កម្រនឹងចេញធ្វើដំណើរណាស់ លើកលែងតែក្នុងថ្ងៃព្រហស្បតិ៍។[12]

11 រាយការណ៍ដោយ អាល់ពូខរី៖២៨៤៨

12 រាយការណ៍ដោយ អាពូហ្ទាវូទ៖៥០៩៤

១២. នៅពេលចេញពីផ្ទះ
ស៊ូណិតសូត្រទូអាពេលចេញពីផ្ទះ ដោយសូត្រថា៖

**«بِسْمِ اللَّهِ، تَوَكَّلْتُ عَلَى اللَّهِ، وَلا حَوْلَ وَلا قُوَّةَ إِلَّا بِاللَّهِ، اللَّهُمَّ إِنِّي أَعُوذُ بِكَ أَنْ أَضِلَّ أَوْ أُضَلَّ، أَوْ أَزِلَّ أَوْ أُزَلَّ، أَوْ أَظْلِمَ أَوْ أُظْلَمَ، أَوْ أَجْهَلَ أَوْ يُجْهَلَ عَلَيَّ» [13].**

بِسْمِ اللَّهِ، تَوَكَّلْتُ عَلَى اللَّهِ، وَلا حَوْلَ وَلا قُوَّةَ إِلَّا بِاللَّهِ، اللَّهُمَّ إِنِّي أَعُوذُ بِكَ أَنْ أَضِلَّ أَوْ أُضَلَّ، أَوْ أَزِلَّ أَوْ أُزَلَّ، أَوْ أَظْلِمَ أَوْ أُظْلَمَ، أَوْ أَجْهَلَ أَوْ يُجْهَلَ عَلَيَّ

មានន័យថា៖ ក្នុងនាមអល់ឡោះ ខ្ញុំសូមប្រគល់ខ្លួនចំពោះទ្រង់។ គ្មានអំណាចឬឥទ្ធិពលអ្វីឡើយ គឺមានតែអល់ឡោះ។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាបញ្ចៀសកុំឱ្យរូបខ្ញុំវង្វេង ឬត្រូវគេធ្វើឱ្យវង្វេង សូមកុំឱ្យរូបខ្ញុំជ្រុលច្រឡំលើផ្លូវខុស ឬត្រូវគេធ្វើឱ្យជ្រុលច្រឡំលើផ្លូវខុស សូមកុំឱ្យរូបខ្ញុំធ្វើប្រការអយុត្តិធម៌ ឬត្រូវគេធ្វើប្រការអយុត្តិធម៌មកលើ និងសូមកុំឱ្យរូបខ្ញុំប្រព្រឹត្តអំពើល្ងង់ខ្លៅ ឬត្រូវគេធ្វើអំពើល្ងង់ខ្លៅមកលើឱ្យសោះ។[13]

១៣. នៅពេលឡើងជិះលើសត្វ រថយន្ត យន្តហោះ ឬយានជំនិះផ្សេងៗទៀត
ស៊ូណិតសូត្រទូអាពេលធ្វើដំណើរដោយសូត្រថា៖ "اللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ، اللَّهُ أَكْبَر" (អល់ឡោះជាម្ចាស់មហាធំធេង

[13] وعثاء السفر: هي شدته. الإفصاح عن معاني الصحاح (4/ 284).

អល់ឡោះជាម្ចាស់មហាធំធេង
អល់ឡោះជាម្ចាស់មហាធំធេង)។ បន្ទាប់មក សូត្រថា៖

**«اللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ ثُمَّ يَقُولُ: {سُبْحَانَ الَّذِي سَخَّرَ لَنَا هَذَا وَمَا كُنَّا لَهُ مُقْرِنِينَ وَإِنَّا إِلَى رَبِّنَا لَمُنْقَلِبُونَ} [الزخرف: 14] اللَّهُمَّ إِنَّا نَسْأَلُكَ فِي سَفَرِنَا هَذَا الْبِرَّ وَالتَّقْوَى، وَمِنَ الْعَمَلِ مَا تَرْضَى، اللَّهُمَّ هَوِّنْ عَلَيْنَا السَّفَرَ، وَاطْوِ عَنَّا بُعْدَهُ، اللَّهُمَّ أَنْتَ الصَّاحِبُ فِي السَّفَرِ، وَالْخَلِيفَةُ فِي الْأَهْلِ، اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ وَعْثَاءِ [14] السَّفَرِ، وَكَآبَةِ المنظر[15]، وسوء الْمُنْقَلَبِ[16] فِي الْمَالِ وَالْأَهْلِ..» [17].**

سُبْحَانَ الَّذِي سَخَّرَ لَنَا هَذَا وَمَا كُنَّا لَهُ مُقْرِنِينَ وَإِنَّا إِلَى رَبِّنَا لَمُنْقَلِبُونَ} { اللَّهُمَّ إِنَّا نَسْأَلُكَ فِي سَفَرِنَا هَذَا الْبِرَّ وَالتَّقْوَى، وَمِنَ الْعَمَلِ مَا تَرْضَى، اللَّهُمَّ هَوِّنْ عَلَيْنَا السَّفَرَ، وَاطْوِ عَنَّا بُعْدَهُ، اللَّهُمَّ أَنْتَ الصَّاحِبُ فِي السَّفَرِ، وَالْخَلِيفَةُ فِي الْأَهْلِ، اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ وَعْثَاءِ السَّفَرِ، وَكَآبَةِ المنظر، وسوء الْمُنْقَلَبِ فِي الْمَالِ وَالْأَهْلِ.

មានន័យថា៖
ទ្រង់ដ៏មហាបរិសុទ្ធដែលទ្រង់បានសម្រួលដល់ពួកយើងខ្ញុំនូវករណីនេះ
ហើយពុំមែនពួកយើងខ្ញុំជាអ្នកមានលទ្ធភាពក្នុងករណីនេះឡើយ។ ពិតណាស់ ពួកយើងនឹងត្រូវវិលត្រឡប់ទៅកាន់ម្ចាស់របស់យើងវិញ។ ឱអល់ឡោះជាម្ចាស់! ពិតណាស់ ពួកយើងសូមបួងសួងចំពោះទ្រង់លើការធ្វើដំណើររបស់យើងខ្ញុំឱ្យស្ថិតក្នុងប្រការល្អ
និងការកោតខ្លាចចំពោះទ្រង់
ព្រមទាំងការប្រតិបត្តិនូវអ្វីដែលទ្រង់យល់ព្រម។
ឱអល់ឡោះជាម្ចាស់!
សូមជួយសម្រួលដល់ការធ្វើដំណើររបស់យើងខ្ញុំនេះឱ្យ

បានងាយស្រួល
និងសូមទ្រង់បង្រួមចម្ងាយនៃដំណើរនេះដល់យើងខ្ញុំផង។ ឱអល់ឡោះជាម្ចាស់! ទ្រង់ជាអ្នកថែរក្សាពួកយើងក្នុងការធ្វើដំណើរ និងជាអ្នកគ្រប់គ្រងលើគ្រួសារ។ ឱអល់ឡោះជាម្ចាស់! ពិតណាស់
ខ្ញុំសូមទ្រង់បញ្ចៀសរូបខ្ញុំពីការលំបាកនៃការធ្វើដំណើរ ការនឿយហត់
និងការផ្លាស់ប្តូរស្ថានភាពពីល្អទៅអាក្រក់ដែលកើតមានឡើងក្នុងគ្រួសារ និងទ្រព្យសម្បត្តិ។[14][15][16][17]

១៤. ស្ងួណិតគួរកុំធ្វើដំណើរតែម្នាក់ឯងដោយគ្មានអ្នករួមដំណើរជាមួយ ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«لَوْ يَعْلَمُ النَّاسُ مَا فِي الْوَحْدَةِ مَا أَعْلَمُ مَا سَارَ رَاكِبٌ بِلَيْلٍ وَحْدَهُ» [18].

“ប្រសិនបើមនុស្សបានដឹងពីគ្រោះថ្នាក់នៃការធ្វើដំណើរម្នាក់ឯងដូចដែលខ្ញុំដឹង
ប្រាកដជាគ្មាននរណាម្នាក់ហ៊ានធ្វើដំណើរតែម្នាក់ឯងនៅពេលយប់ឡើយ”។[18]

---

14 រាយការណ៍ដោយ អាល់ពូខរី៖២៩៩៨

15 រាយការណ៍ដោយអះម៉ាត់នៅក្នុងសៀវភៅមុសណាត់របស់គាត់៖៦៣៧៤

16 المنقلب): هو الرجوع. الإفصاح عن معاني الصحاح (4/ 284)

17 سوء الهيئة والانكسار من الحزن. الإفصاح عن معاني الصحاح (4/ 284).

18 រាយការណ៍ដោយ អាពូហ្សាវូទ៖២៦០៨

១៥. អ្នកដែលធ្វើដំណើរត្រូវជ្រើសរើសម្នាក់ក្នុងចំណោមក្រុមរបស់ខ្លួនធ្វើជាមេដឹកនាំដើម្បីរក្សាសាមគ្គីភាព និងសម្រេចគោលបំណងរួម។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«إِذَا خَرَجَ ثَلَاثَةٌ فِي سَفَرٍ فَلْيُؤَمِّرُوا أَحَدَهُمْ» [19].

"នៅពេលដែលមនុស្សបីនាក់ធ្វើដំណើរ ចូរឲ្យពួកគេជ្រើសតាំងម្នាក់ក្នុងចំណោមពួកគេធ្វើជាមេដឹកនាំ"។[19]

១៦. ត្រូវព្យាយាមបំពេញនូវកាតព្វកិច្ចទាំងឡាយដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្គាប់ប្រើ និងចៀសវាងឲ្យឆ្ងាយពីអ្វីដែលទ្រង់បានហាមឃាត់ ព្រមទាំងប្រកាន់ខ្ជាប់នូវសីលធម៌ថ្លៃថ្នូរ ល្អប្រពៃ។ ត្រូវជួយដល់អ្នកដែលត្រូវការជំនួយ ចែករំលែកចំណេះដឹងដល់អ្នកដែលស្វែងរកវា និងអ្នកដែលត្រូវការវា ហើយត្រូវមានចិត្តសប្បុរសចំពោះទ្រព្យសម្បត្តិរបស់ខ្លួនដោយត្រូវចំណាយវាដើម្បីជាប្រយោជន៍ដល់ខ្លួនឯងក៏ដូចជាប្រយោជន៍ដល់បងប្អូនរបស់គេ និងបំពេញនូវសេចក្តីត្រូវការរបស់ពួកគេ។

១៧. គួរត្រៀមលុយកាក់ និងរបស់របរចាំបាច់សម្រាប់ការធ្វើដំណើរឲ្យបានគ្រ

---

19 រាយការណ៍ដោយអះម៉ាត់នៅក្នុងសៀវភៅមុសណាត់របស់គាត់៖១៧៧៦៣

ប់គ្រាន់ ព្រោះអាចមានករណីអ្វីមួយកើតឡើងភ្លាមៗ ឬក៏ស្ថានការណ៍មានការផ្លាស់ប្ដូរបន្ទាន់។

១៨. ក្នុងអំឡុងពេលធ្វើដំណើរ គប្បីមានទឹកមុខញញឹមរីករាយ ចិត្តល្អ និងព្យាយាមធ្វើឲ្យមិត្តរួមដំណើរជាមួយសប្បាយចិត្ត ដើម្បីឲ្យមានភាពស្និទ្ធស្នាលនឹងគ្នា។

១៩. គប្បីអត់ធ្មត់ចំពោះភាពឆ្គាំឆ្គង ឬការខ្វែងគំនិតគ្នាពីសំណាក់មិត្តរួមដំណើរ និងត្រូវដោះស្រាយបញ្ហាដោយសន្តិវិធី ដើម្បីទទួលបានការគោរព និងការឲ្យតម្លៃពីពួកគេ។

២០. នៅពេលដែលអ្នកដំណើរទាំងឡាយចុះចតនៅកន្លែងណាមួយ ស៊ូណិតគប្បីនៅជុំគ្នា។ ពិតប្រាកដណាស់ កាលពីមុន សហាហ្ពាត់មួយចំនួនរបស់ណាពី ﷺ នៅពេលដែលពួកគេចុះចតនៅកន្លែងណាមួយ គឺពួកគេនៅបែកខ្ញែកគ្នាទៅតាមច្រក និងជ្រលងនានា។ ពេលនោះ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«إِنَّ تَفَرُّقَكُمْ فِي الشِّعَابِ وَالْأَوْدِيَةِ إِنَّمَا ذَلِكُمْ مِنَ الشَّيْطَانِ» [20]،

“ពិតប្រាកដណាស់ ការដែលពួកអ្នកបែកខ្ញែកគ្នានៅតាមច្រក និងជ្រលងទាំងនេះ តាមពិត នោះគឺមកពីស្ហៃតន”។[20] ចាប់តាំងពីពេលនោះមក

[20] រាយការណ៍ដោយ មូស្លីមៈ២៧០៨

ពួកគេក៏ចាប់ផ្តើមនៅជុំគ្នា រហូតដល់ថា បើគេយកក្រណាត់មួយផ្ទាំងមកក្រាលពីលើពួកគេ វានឹងគ្របដណ្តប់ពួកគេទាំងអស់គ្នា។

២១. នៅពេលដែលគេចុះចតនៅកន្លែងណាមួយ ស៊ុណ្ណិតសូត្រទូអាដូចដែលមានបញ្ជាក់ពីណាពី ﷺ ថា៖

«أَعُوذُ بِكَلِمَاتِ اللَّهِ التَّامَّاتِ مِنْ شَرِّ مَا خَلَقَ» [21]؛

أَعُوذُ بِكَلِمَاتِ اللَّهِ التَّامَّاتِ مِنْ شَرِّ مَا خَلَقَ

មានន័យថា៖

ខ្ញុំសុំបញ្ចៀសតាមរយៈពាក្យពេចន៍ដ៏ពេញលេញរបស់អល់ឡោះពីប្រការអាក្រក់នៃអ្វីដែលទ្រង់បានបង្កើត។ [21] ប្រសិនបើគេសូត្រដូចនេះ គ្មានអ្វីអាចបង្កគ្រោះថ្នាក់ដល់គេបានឡើយ រហូតដល់គេចាកចេញពីកន្លែងនោះ។

២២. ស៊ុណ្ណិតតឹកពៀរ(សូត្រថា៖ الله أكبر)នៅពេលឡើងទីខ្ពស់ និងតាសពេស្ហ(សូត្រថា៖ سبحان الله)នៅពេលចុះចំណោត និងជ្រលងនានា។ ជើពៀរ رضي الله عنه បាននិយាយថា៖ កាលណាពួកយើងឡើងទីខ្ពស់ គឺពួកយើងតឹកពៀរ។ ហើយនៅពេលពួកយើងចុះ(ចំណោត) គឺពួកយើងតាសពេស្ហ។[22]

មិនត្រូវបន្លឺសំឡេងតឹកពៀរខ្លាំងៗឡើយ។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

---

21 រាយការណ៍ដោយ អាល់ពូខរី៖២៩៩៤

22 រាយការណ៍ដោយ អាល់ពូខរី៖២៩៩៣

«يَا أَيُّهَا النَّاسُ ارْبَعُوا عَلَى أَنْفُسِكُمْ فَإِنَّكُمْ لَا تَدْعُونَ أَصَمَّ وَلَا غَائِبًا إِنَّهُ مَعَكُمْ إِنَّهُ سَمِيعٌ قَرِيبٌ» [23].

“ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកអាណិតអាសូរចំពោះខ្លួនឯង ព្រោះពួកអ្នកមិនមែនកំពុងតែបួងសួងដល់អ្នកដែលថ្លង់ និងអ្នកដែលមិនមាននៅទីនោះឡើយ។ ជាការពិតណាស់ ទ្រង់នៅជាមួយអ្នក។ ពិតណាស់ ទ្រង់មហាឮ និងនៅជិតបំផុត”។[23]

២៣. ស៊ូណិតធ្វើដំណើរនៅពេលរាត្រី ជាពិសេសនៅដើមរាត្រី ដូចដែលណាពី ﷺ លោកបានមានប្រសាសន៍ថា៖

««عَلَيْكُمْ بِالدُّلْجَةِ؛ فَإِنَّ الْأَرْضَ تُطْوَى بِاللَّيْلِ» [24].

“ចូរពួកអ្នកធ្វើដំណើរនៅពេលរាត្រី ព្រោះផែនដីត្រូវគេមូរនៅពេលរាត្រី”។[24]

២៤. ស៊ូណិតធ្វើការបួងសួងឱ្យបានច្រើននៅពេលធ្វើដំណើរ ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«ثَلَاثُ دَعَوَاتٍ مُسْتَجَابَاتٌ لَا شَكَّ فِيهِنَّ: دَعْوَةُ الْمَظْلُومِ، وَدَعْوَةُ الْمُسَافِرِ، وَدَعْوَةُ الْوَالِدِ عَلَى وَلَدِهِ» [25].

“ការបួងសួងបីយ៉ាងនឹងត្រូវគេទទួលយកដោយគ្មានការសង្ស័យឡើយ

---

23 រាយការណ៍ដោយ អាពូហ្ទាវូទ៖២៩៧១

24 រាយការណ៍ដោយអះម៉ាត់នៅក្នុងសៀវភៅមុសណាត់របស់គាត់៖១០៧៧១

គឺការបួងសួងរបស់អ្នកដែលត្រូវគេបំពាន ការបួងសួងរបស់អ្នកដែលធ្វើដំណើរ និងការបួងសួងរបស់ឪពុកម្តាយឲ្យកូនរបស់ខ្លួន”។[25]

***

## ទីពីរ៖ ការជម្រះខ្លួនក្នុងពេលធ្វើដំណើរ

អ្នកធ្វើដំណើរត្រូវយកចិត្តទុកដាក់តែថែរក្សាភាពស្អាតរបស់ខ្លួន ដោយត្រូវធ្វើការលាងជម្រះ (វូហ្ទុ) សម្រាប់ហាទេសតូច និងងូតទឹកសម្រាប់ហាទេសធំ។

ប្រសិនបើមិនមានទឹក ឬមានទឹកតិចដែលត្រូវការសម្រាប់អាហារនិងផឹក គាត់អាចធ្វើតាយ៉ាំមុំបាន។

របៀបធ្វើតាយ៉ាំមុំ៖ គឺទះដៃទាំងពីរប៉ះដី រួចជូតមុខនិងប្រអប់ដៃទាំងពីរ។

ការជម្រះខ្លួនដោយតាយ៉ាំមុំគឺជាការជម្រះបណ្តោះអាសន្ន។ នៅពេលមានទឹក វានឹងបាត់បង់សុពលភាព ហើយត្រូវប្រើទឹកវិញ។ ប្រសិនបើធ្វើតាយ៉ាំមុំសម្រាប់ហាទេសធំ ហើយរកបានទឹក ត្រូវងូតទឹក។ ប្រសិនបើធ្វើតាយ៉ាំមុំក្រោយពីបត់ជើងធំ ហើយរកបានទឹក ត្រូវធ្វើវូហ្ទុ។ ដូចមានក្នុងហាទីសថា៖

«الصَّعِيدُ الطَّيِّبُ وَضُوءُ المُسْلِمِ وَإِنْ لَمْ يَجِدِ المَاءَ عَشْرَ سِنِينَ، فَإِذَا وَجَدَ المَاءَ فَلْيَتَّقِ اللَّهَ، وَلْيُمِسَّهُ بَشَرَتَهُ» [26].

25 រាយការណ៍ដោយអាល់ពូហៀរនៅក្នុងសៀវភៅមុសណាត់របស់គាត់៖១០០៦៨

“ដីដែលស្អាត គឺជាទឹកវូហ្ទុររបស់អ្នកមូស្លីម ទោះបីជាគេគ្មានទឹករយៈពេលដប់ឆ្នាំក៏ដោយ។ ប៉ុន្តែនៅពេលណាដែលគេមានទឹក ចូរឲ្យគេកោតខ្លាចអល់ឡោះ ហើយចូរឲ្យទឹកនោះប៉ះស្បែករបស់គេ(ប្រើទឹកយកវូហ្ទុរិញ)”។[26]

ការជូតលើស្បែកជើងត្រូវបានអនុញ្ញាតដោយគម្ពីរគួរអាន និងសុណ្ណះ និងការឯកភាពរបស់អះលូសស៊ុណ្ណះ។

លក្ខខណ្ឌនៃការជូតលើស្បែកជើងនិងអ្វីដែលស្រដៀងគ្នាមានដូចខាងក្រោម៖

១. ស្បែកជើងឃ្លុបឬស្រោមជើងនោះត្រូវតែជារបស់ដែលគេអនុញ្ញាត និងមានភាពជ្រះស្អាត។

២. ត្រូវពាក់វាក្នុងពេលដែលគេមានភាពជ្រះស្អាត(មានវូហ្ទុ)។

៣. ត្រូវគ្របជិតកន្លែងដែលចាំបាច់។

៤. អាចជូតបានសម្រាប់តែហាហ្ទាសតូចប៉ុណ្ណោះ។ ដូចនេះ គេមិនអនុញ្ញាតឲ្យជូតសម្រាប់ហាហ្ទាសធំ ហើយនិងអ្វីដែលចាំបាច់តម្រូវឲ្យងូតទឹកនោះឡើយ។

៥. ត្រូវជូតក្នុងអំឡុងពេលដែលច្បាប់ឥស្លាមបានកំណត់

---

26 រាយការណ៍ដោយ អាល់ពូខរី៖១៨០៤, មូស្លីម៖១៩២៧

គឺមួយថ្ងៃមួយយប់សម្រាប់អ្នកមិនធ្វើដំណើរ និងបីថ្ងៃបីយប់សម្រាប់អ្នកធ្វើដំណើរ។ រយៈពេលនេះគឺគិតចាប់ពីពេលជូតលើកដំបូងក្រោយដាច់ទឹករំលាយ ហើយបញ្ចប់នៅ២៤ម៉ោងក្រោយសម្រាប់អ្នកដែលមិនធ្វើដំណើរ
និងនៅ៧២ម៉ោងក្រោយសម្រាប់អ្នកដែលធ្វើដំណើរ។

ការជូតលើស្បែកជើងនឹងត្រូវខូចដោយករណីបីយ៉ាង៖

១. នៅពេលកើតមាននូវប្រការទាំងឡាយណាដែលចាំបាច់លើគេត្រូវងូតទឹក ដូចជាមានជូនុបជាដើម ការជូតនោះត្រូវខូច ហើយចាំបាច់លើគេត្រូវងូតទឹក។

២. នៅពេលដែលគេដោះស្បែកជើងនោះចេញក្រោយពីបានជូតរួច។

៣. នៅពេលផុតរយៈពេលដែលច្បាប់ឥស្លាមបានកំណត់។

***

## ទី៣៖ បទបញ្ញត្តិនៃការកាត់បន្ថយការថ្វាយបង្គំ(សឡាតក៏សើរ) ក្នុងពេលធ្វើដំណើរ៖

ការកាត់បន្ថយ(សឡាតក៏សើរ)ក្នុងពេលធ្វើដំណើរល្អជាងការធ្វើពេញលេញ។ ប៉ុន្តែប្រសិនបើអ្នកធ្វើដំណើរធ្វើការថ្វាយបង្គំទាំង ៤

រ៉ក្អាត់ ការថ្វាយបង្គំរបស់គាត់នៅតែត្រឹមត្រូវ ប៉ុន្តែគាត់បានធ្វើផ្ទុយនឹងអ្វីដែលល្អបំផុត។

អ្នកធ្វើដំណើរអាចកាត់បន្ថយសឡាត(សឡាតក៏សើរ)នៅពេលគាត់ចេញផុតពីភូមិ ឬទីក្រុងរបស់គាត់។ នេះគឺជាទស្សនៈរបស់អ្នកប្រាជ្ញអ៊ីស្លាមភាគច្រើន។

ប្រសិនបើគាត់ធ្វើដំណើរក្រោយពេលចូលម៉ោងថ្វាយបង្គំ គាត់អាចកាត់បន្ថយ(សឡាតក៏សើរ)វាបាន ព្រោះគាត់បានធ្វើដំណើរមុនពេលអស់ម៉ោង។

ចំពោះការរួមបញ្ចូលគ្នារវាងការថ្វាយបង្គំស៊ូហ៊្វរនិងអាសើរ និងរវាងពេលម៉ាហ្គ្រិបនិងអ៊ីសា វាគឺជាសុណ្ណៈសម្រាប់អ្នកធ្វើដំណើរនៅពេលត្រូវការ នៅពេលគាត់កំពុងបន្តដំណើរ។ គាត់អាចធ្វើអ្វីដែលងាយស្រួលសម្រាប់គាត់ ដោយរួមបញ្ចូលគ្នាមុន ឬក្រោយ។

តែប្រសិនបើអ្នកដំណើរមិនមានតម្រូវការក្នុងការផ្គុំសឡាតទេនោះ គឺគេមិនគួរផ្គុំសឡាតឡើយ។ ឧទាហរណ៍៖ ប្រសិនបើគេចុះចតនៅកន្លែងណាមួយ ហើយគេមិនមានបំណងចាកចេញពីទីនោះឡើយ រហូតដល់ម៉ោងសឡាតទីពីរចូលមកដល់ ក្នុងករណីនេះ ជាការប្រសើរ គឺមិនគួរផ្គុំសឡាតឡើយ ពីព្រោះគេមិនមានតម្រូវការក្នុងការធ្វើដូច្នោះឡើយ។ ហេតុនេះហើយទើបណាពី ﷺ លោកមិនបានផ្គុំសឡាតនៅពេលលោកស្នាក់នៅមី

ណាក្នុងពេលធ្វើហាជ្ជីលានោះឡើយ ដោយសារតែមិនមានតម្រូវការក្នុងការធ្វើដូច្នោះ។

ចំពោះការថ្វាយបង្គំស្ម័គ្រចិត្ត(សឡាតស៊ូណាត់) អ្នកធ្វើដំណើរអាចធ្វើការថ្វាយបង្គំស្ម័គ្រចិត្តដូចអ្នកស្នាក់នៅអចិន្ត្រៃយ៍ដែរ។ គាត់អាចថ្វាយបង្គំពេលព្រឹក(ទូហា) ពេលយប់ និងការថ្វាយបង្គំផ្សេងៗទៀត លើកលែងតែការថ្វាយបង្គំស៊ូណាត់រ៉ាវ៉ាទិបនៃពេលស៊ូហ៊ូរ និងម៉ាគ្រីប អ៊ីសា ដែលតាមសុណ្ណៈគឺមិនថ្វាយបង្គំឡើយ។

ការថ្វាយបង្គំស្ម័គ្រចិត្តអាចធ្វើបាននៅលើយានជំនិះក្នុងពេលធ្វើដំណើរៈ លើយន្តហោះ រថយន្ត នាវា និងមធ្យោបាយធ្វើដំណើរផ្សេងទៀត។ ចំពោះការថ្វាយបង្គំកាតព្វកិច្ច ត្រូវតែចុះពីយានជំនិះ លើកលែងតែពេលមិនអាចធ្វើបាន។

ការថ្វាយបង្គំរបស់អ្នកធ្វើដំណើរតាមក្រោយអ្នកស្នាក់នៅផ្ទះគឺត្រឹមត្រូវ។ អ្នកធ្វើដំណើរត្រូវថ្វាយបង្គំពេញលេញដូចអ៊ីម៉ាំរបស់គាត់ មិនថាគាត់ទាន់ការថ្វាយបង្គំទាំងមូលមួយរ៉ក្កាត់ ឬតិចជាងនេះ។ សូម្បីតែប្រសិនបើគាត់ចូលរួមក្នុងតាស្ហាស់ហ៊ុតចុងក្រោយមុនពេលឲ្យសាឡាម គាត់ត្រូវតែថ្វាយបង្គំពេញលេញ។ នេះគឺជាការយល់ឃើញត្រឹមត្រូវក្នុងចំណោមទស្សនៈរបស់អ្នកប្រាជ្ញអ៊ីស្លាម។

***

## ទីបួន៖
## សុជីវធម៌នៃការវិលត្រឡប់មកពីធ្វើហាជ្ជីនិងអ៊ុមរ៉ោះ ឬវិលត្រឡប់ពីការធ្វើដំណើរវិញ

គួរប្រញាប់ប្រញាល់ត្រឡប់មកវិញ និងមិនគួរស្នាក់នៅយូរពេកក្នុងការធ្វើដំណើរដោយគ្មានហេតុផលត្រឹមត្រូវ។ ដូចប្រសាសន៍របស់ព្យាការី ﷺ បានមានប្រសាសន៍ថា៖

«السَّفَرُ قِطْعَةٌ مِنَ الْعَذَابِ، يَمْنَعُ أَحَدَكُمْ طَعَامَهُ وَشَرَابَهُ وَنَوْمَهُ، فَإِذَا قَضَى نَهْمَتَهُ فَلْيُعَجِّلْ إِلَى أَهْلِهِ» [27].

“ការធ្វើដំណើរ គឺជាផ្នែកមួយនៃទណ្ឌកម្ម។ វាបានរារាំងម្នាក់ៗនៃពួកអ្នកពីម្ហូបអាហារ ទឹក និងការដេក។ ហេតុនេះ នៅពេលដែលគេសម្រេចភារកិច្ចរបស់ខ្លួនហើយនោះ ចូរឲ្យគេរួសរាន់វិលត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ខ្លួនវិញ”។[27]

នៅពេលដែលគេចង់ត្រឡប់ទៅស្រុកកំណើតវិញ គប្បីសូត្រទូអាពេលធ្វើដំណើរនៅពេលឡើងជិះយានជំនិះ ហើយបន្ថែមថា៖

«آيِبُونَ تَائِبُونَ عَابِدُونَ لِرَبِّنَا حَامِدُونَ» [28].

“آيِبُونَ تَائِبُونَ عَابِدُونَ لِرَبِّنَا حَامِدُونَ”

(ពួកយើងវិលត្រឡប់វិញ ពួកយើងសារភាពកំហុស ពួកយើងគោរពសក្ការៈ

---

27 រាយការណ៍ដោយ អាល់ពូខរី៖១៧៩៧, មូស្លីម៖១៣៤២

និងថ្លែងសរសើរទៅចំពោះព្រះជាម្ចាស់របស់ពួកយើង)
។[28]

នៅពេលត្រឡប់មកវិញ ស៊ូណិតលើគេគប្បីសូត្រនូវអ្វីដែលមានបញ្ជាក់ពីណាពី ﷺ ដែលថា កាលណាលោកត្រឡប់មកពីធ្វើសង្គ្រាម ឬមកពីធ្វើហាជ្ជី ឬអ៊ុមរ៉ោះវិញ លោកតែងតឹកពៀរបីដងនៅពេលឡើងកន្លែងខ្ពស់ៗ។ បន្ទាប់មក លោកសូត្រថាៈ

**«لَا إِلَهَ إِلَّا اللّهُ، وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ، وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، آيِبُونَ، تَائِبُونَ، عَابِدُونَ، سَاجِدُونَ، لِرَبِّنَا حَامِدُونَ، صَدَقَ اللّهُ وَعْدَهُ، وَنَصَرَ عَبْدَهُ، وَهَزَمَ الْأَحْزَابَ وَحْدَهُ» [29].**

لَا إِلَهَ إِلَّا اللهُ، وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ، وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، آيِبُونَ، تَائِبُونَ، عَابِدُونَ، سَاجِدُونَ، لِرَبِّنَا حَامِدُونَ، صَدَقَ اللهُ وَعْدَهُ، وَنَصَرَ عَبْدَهُ، وَهَزَمَ الْأَحْزَابَ وَحْدَه

(គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះមួយគត់ គ្មានទេស្ហ៊ីរិកទៅចំពោះទ្រង់។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់។ ពួកយើងវិលត្រឡប់វិញ ពួកយើងសារភាពកំហុស ពួកយើងគោរពសក្ការៈ ពួកយើងស៊ូជោត និងថ្លែងសរសើរទៅចំពោះព្រះជាម្ចាស់របស់ពួកយើង។ អល់ឡោះបានបំពេញតាមការសន្យារបស់ទ្រង់ ជួយដល់ខ្ញុំបម្រើរបស់ទ្រង់

---

28 រាយការណ៍ដោយ អាល់ពូខរីៈ៤១១៦

និងធ្វើឲ្យក្រុមទាំងឡាយបរាជ័យដោយស្នាដៃទ្រង់តែម្នាក់គត់)។[29]

នៅពេលដែលបានឃើញស្រុកទេស ឬស្រុកភូមិរបស់ខ្លួន ស៊ូណិតសូត្រថា៖

«آيِبُونَ تَائِبُونَ عَابِدُونَ لِرَبِّنَا حَامِدُونَ» [30]،

"آيِبُونَ تَائِبُونَ عَابِدُونَ لِرَبِّنَا حَامِدُونَ"

(ពួកយើងវិលត្រឡប់វិញ ពួកយើងសារភាពកំហុស ពួកយើងគោរពសក្ការៈ និងថ្លែងសរសើរទៅចំពោះព្រះជាម្ចាស់របស់ពួកយើង)។[30] ហើយសូត្រវាដដែលៗ រហូតដល់ចូលក្នុងស្រុកទេស ឬស្រុកភូមិរបស់ខ្លួន ដោយយោងតាមទង្វើរបស់ណាពី ﷺ ។

ប្រសិនបើគេឃ្លាតឆ្ងាយពីផ្ទះរយៈពេលយូរ គឺគេមិនគួរត្រឡប់មកផ្ទះនៅពេលយប់ដោយគ្មានការចាំបាច់ឡើយ លើកលែងតែគេបានជូនដំណឹងដល់ក្រុមគ្រួសារជាមុន និងបានប្រាប់ក្រុមគ្រួសារពីពេលវេលាដែលខ្លួននឹងមកដល់នៅពេលយប់ ព្រោះណាពី ﷺ លោកបានហាមឃាត់ពីរឿងនេះ។ ជើពៀរ ពិន អាប់ទុលឡោះ رضي الله عنهما បាននិយាយថា៖

«نَهَى رَسُولُ اللهِ صلى الله عليه وسلم أَنْ يَطْرُقَ الرَّجُلُ أَهْلَهُ لَيْلًا» [31]،

---

29 រាយការណ៍ដោយ អាល់ពូខរី៖១៧៩៧, មូស្លីម៖១៣៤២

30 រាយការណ៍ដោយ មូស្លីម៖៧១៥

រ៉ស៊ូលុលឡោះ ﷺ
លោកបានហាមឃាត់បុរសចំពោះការត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ខ្លួនវិញនៅពេលយប់។[31]
ចំពោះហេតុផលនៃការហាមឃាត់នេះ
គឺត្រូវបានពន្យល់ក្នុងហាទីស្ហមួយផ្សេងទៀតថា៖
«حتَّى تَمْتَشِطَ الشَّعِثَةُ [32]، وَتَسْتَحِدَّ الْمَغِيبَةُ» [33]،

"ដើម្បីឱ្យស្ត្រីដែលសក់មិនរៀបរយបានសិតសក់របស់នាង
និងឱ្យស្ត្រីដែលប្តីរបស់នាងអវត្តមាននោះបានសម្អាតរោមចេញពីផ្នែកឯកជនរបស់នាង(រៀបចំខ្លួនរបស់នាង)"។[32][33]
ចំណែកឯនៅក្នុងហាទីស្ហមួយផ្សេងទៀត៖
«نَهَى رَسُولُ اللهِ صلى الله عليه وسلم أَنْ يَطْرُقَ الرَّجُلُ أَهْلَهُ لَيْلًا، يَتَخَوَّنُهُمْ أَوْ يَلْتَمِسُ عَثَرَاتِهِمْ» [34].
រ៉ស៊ូលុលឡោះ ﷺ
លោកបានហាមឃាត់បុរសចំពោះការត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ខ្លួនវិញនៅពេលយប់
ដូចជាអ្នកដែលមករកពេលយប់
ព្រោះខ្លាចកើតមានរឿង(ដែលមិននឹកស្មានដល់)

31 الشعثة): التي طال عهدها بالدهن والمشط، و (الاستحداد): استعمال الحديد، و (المغيبة): التي غاب زوجها.التحرير في شرح صحيح مسلم - الأصبهاني (ص292)

32 រាយការណ៍ដោយ មូស្លីម៖៧១៥

33 រាយការណ៍ដោយ អាន់ណាសាអ៊ី៖៩០៩៩]

សង្ស័យលើភាពស្មោះត្រង់របស់ពួកគេ និងការតាមចាប់កំហុសរបស់ពួកគេ។[34]

គប្បី(ស៊ូណាត់)ឱ្យអ្នកត្រលប់មកពីធ្វើដំណើរ ចូលទៅក្នុងម៉ាស្ជិតដែលនៅជិតគាត់ និងសឡាត(ថ្វាយបង្គំ) ពីររ៉ក្អាត់ ដោយធ្វើតាមគំរូរបស់ព្យាការី ﷺ។

គប្បី(ស៊ូណាត់)ឱ្យអ្នកធ្វើដំណើរនៅពេលត្រលប់មកពីធ្វើដំណើរ ប្រព្រឹត្តល្អចំពោះក្មេងៗនៅក្នុងគ្រួសាររបស់គាត់និងអ្នកជិតខាង នៅពេលពួកគេមកទទួល។ ដូចដែលបានរាយការណ៍ដោយអ៊ិបនូអាប់ហ្គាស់(សូមអល់ឡោះពេញចិត្តដល់គាត់ទាំងពីរ) បាននិយាយថាៈ នៅពេលព្យាការីបានមកដល់ម៉ាក្កះ ក្មេងប្រុសៗនៃអំបូរអាប់ឌុលមូត្តឡឹបបានមកទទួល ហើយគាត់បានលើកម្នាក់នៅខាងមុខនិងម្នាក់ទៀតនៅខាងក្រោយ។ អាប់ឌុលឡោះ ពិន ចាក់ហ្វើរ(សូមអល់ឡោះពេញចិត្តដល់គាត់) បាននិយាយថាៈ

"كَانَ النَّبِيُّ صَلَّى الله عليه وَسَلَّمَ إِذَا قَدِمَ مِنْ سَفَرٍ تُلُقِّيَ بِنَا، قَالَ: فَتُلُقِّيَ بِي وَبِالْحَسَنِ أَوْ بِالْحُسَيْنِ، قَالَ: فَحَمَلَ أَحَدَنَا بَيْنَ يَدَيْهِ وَالْآخَرَ خَلْفَهُ حَتَّى دَخَلْنَا الْمَدِينَةَ" [35].

កាលណាណាពី ﷺ ត្រលប់មកពីការធ្វើដំណើរ លោករាក់ទាក់ស្វាគមន៍ពួកយើង។ ថ្ងៃមួយនោះ ខ្ញុំ និងហាសាន់ ឬហ៊ូសេន បានជួបលោក ។

---

34 រាយការណ៍ដោយ មូស្លីមៈ២៤២៨

**គាត់បានបន្តថា៖ ពេលនោះ លោកបានពរម្នាក់ដាក់នៅខាងមុខ និងម្នាក់ទៀតដាក់នៅខាងក្រោយ រហូតដល់យើងចូលទៅក្នុងទីក្រុងម៉ាទីណះ។**[35]

គប្បី(ស៊ូណាត់)ផ្តល់អំណោយគឺជាការល្អ ព្រោះវាធ្វើឱ្យចិត្តស្រស់ស្រាយនិងបំបាត់ការស្អប់។ គួរឱ្យទទួលយកអំណោយនិងតបស្នងវិញ ហើយមិនគួរបដិសេធដោយគ្មានហេតុផលតាមច្បាប់សាសនា។ នេះជាមូលហេតុដែលព្យាការីបាននិយាយថា៖

**«تَهَادُوا تَحَابُّوا» [36].**

**“ចូរពួកអ្នកផ្តល់កាដូឱ្យគ្នាទៅវិញទៅមក នោះអ្នកនឹងស្រលាញ់គ្នា”។**[36]

អំណោយគឺជាមូលហេតុមួយនៃការស្រលាញ់រវាងអ្នកមូស្លីម។

នៅពេលអ្នកធ្វើដំណើរត្រលប់មកដល់ប្រទេសរបស់គាត់ គប្បី(ស៊ូណាត់)ឱ្យមានការឱបគ្នា ដែលបានបញ្ជាក់ដោយមិត្តភក្តិ(សហាហ្ពាត់)របស់ព្យាការី ដូចដែលអាណាស់(សូមអល់ឡោះពេញចិត្តដល់គាត់) បាននិយាយថា៖ នៅពេលពួកគេជួបគ្នា ពួកគេចាប់ដៃគ្នា។

---

35 រាយការណ៍ដោយអាល់ពៃហាគីនៅក្នុងសៀវភៅ អាស់ស៊ូណាន់ អាល់គុបរ៉ះ១១៩៤៦

36 រាយការណ៍ដោយ អាត់តប់រ៉នីក្នុងសៀវភៅ អាល់អាវសត់៖៩៧

ហើយនៅពេលពួកគេត្រលប់មកពីធ្វើដំណើរ ពួកគេឱបគ្នា។[37]

وصلى الله وسلم على نبينا محمد

[37] រាយការណ៍ដោយ អាល់ពូខរី៖៣១១៦, មូស្លីម៖១០០

# Index

សុជីវធម៌ និងក្បួនច្បាប់នៃការធ្វើដំណើរ 2
ទីមួយៈ សុជីវធម៌នៃការធ្វើដំណើរ 2
ទីពីរៈ ការជម្រះខ្លួនក្នុងពេលធ្វើដំណើរ 23
ទីបីៈ បទបញ្ញត្តិនៃការកាត់បន្ថយការថ្វាយបង្គំ(សឡាតក៏សើរ) ក្នុងពេលធ្វើដំណើរៈ 27
ទីបួនៈ សុជីវធម៌នៃការវិលត្រឡប់មកពីធ្វើហាជ្ជីនិងអ៊ុមរ៉ោះ ឬវិលត្រឡប់ពីការធ្វើដំណើរវិញ 30